
SBS
SOVYCHEA BOOK SHOP
ព្រានសន្ទូច
The Fisherman



មានគ្រួសារមួយរស់នៅជនបទ ប្រកបរបរស្ទូចត្រី ។ ថ្ងៃមួយឪពុកនាំកូនទៅរកត្រីឯស្ទឹង ទុកប្រពន្ធឱ្យនៅចាំផ្ទះ ។

There was a family lived in a country. They are fishermen. One day father brought his son to fish at a tributary, and his wife stayed at home.

នៅឯស្ទឹង នាយព្រានរៀបចំប្រដាប់ប្រដាស្ទូចក្រោមម្លប់ឈើសាខា ដោយមិន
ភ្លេចចោលផ្លែញញឹមទៅលើផ្ទៃទឹកទន្ទឹមពេល រង់ចាំកូនយកនុយជង្ហូវខ្លងឱ្យ ។ ត្រីរក
រាយ១គូបែរភ័យបុកពោះសើចលែងសម  ពេលហែបឡើងយល់មុខព្រាន ។



At the tributary, there was a shadow of a big tree. Under a big shadow, the fisherman prepared fishing pole and waited his son to bring him worm decoy. He was happy while he was throwing a fishing hook into the water. A pair of happy fish was very fear, when they swam and rose up to get air, and saw them.



បាននុយដង្កូវគ្រប់គ្រាន់ហើយ ឪពុកនិងកូននាំគ្នាស្ទូច តាមទីដោយឡែករៀងខ្លួន ។ ស្ទូចបានបន្តិច ស្រាប់តែសន្ទូចខាងឪពុក តឹងញ័រ វាត់ឡើងមិនរួច ។



After there was enough baits, father and son began to fish in different place. A little moment fishing, the fishing pole of the father unable to swing up, fishing line was tight and trembled.





នាយព្រានទឹកត្រេកអរសំគាល់ថា ត្រីធំស៊ីសន្ទូចហើយ ។ គិតឃើញដូច្នោះ ចៅនោះក៏ម្នីម្នាចងដងសន្ទូចយ៉ាងមាំភ្ជាប់ទៅមែកឈើ រួចងាកមកដេញកូនប្រុសឱ្យទៅផ្ទះ....។



The fisherman thought that a big fish ate his bait. So he tied fishing pole very tightly at a branch of the tree, and turned to his son and told him to go home…

នៅឯផ្ទះ កុមារកូនរាយការណ៍ឡូងៗពីរឿង ត្រីធំស៊ីសន្ទូចតាំងពីក្រោរបង ។ កុមារប្រាប់ម្ដាយ ឱ្យដើរបង្គជម្លោះជាមួយញាតិជិតខាង តាមដូចការបង្គាប់ពីឪពុក ដើម្បីកាល់ហាម កុំឱ្យពួកញាតិនោះ ចូលលេងផ្ទះសុំត្រីស៊ីបាន ។



At home, the son announced very loudly outside their house fence about a big fish ate the bait of his father. The boy told his mother to quarrel with neighbors. The boy told her about what the father wanted to do. They did like that might be the neighbors enter their house and begged for fish.



ប្រពន្ធព្រានយល់ការណ៍ ក៏យកធ្យូងផ្ទាំងសំលលាបមុខ ចោមពុងក្រមា ស្លៀកសំពត់សំយេះក្រោមផ្ចិត រួចហើយដើរសំដៅទៅកាន់ផ្ទះញាតិជិតខាង ។ បណ្តាញាតិប្រុសស្រី កាលបានឃើញកិរិយានាងព្រានប្លែកដូច្នោះ ក៏នាំគ្នាសើចនិងសួរទៅតាមដំណើរដែលឃើញ ។ ឯនាងព្រាននោះ និមិត្តតែឮញាតិណាសើចឬសួរ ក៏តាំងបានលេសស្រែកជេរបញ្ឆោរ ក្តែងៗភ្លាមទៅ ។



The wife of the fisherman knew about that, so she took the black dirt of pot applied on her face. And then she wore Sarong (Kind of long skirt wore by women) under her navel and wrapped the cotton scarf around her bosom. After that, she walked toward neighbor's houses. When the neighbors saw the strange attitude of her they laughed at her and asked questions what they saw. Because of those reasons she yelled and cursed at them.





ពួកញាតិខ្លះខំអត់ស្ងៀមនៅ ខ្លះជេរតបតវិញ ។ អ្នកខ្លះទៀតខឹងខ្លាំងមិនសុខចិត្ត ក៏ធ្វើការប្តឹងដល់ចៅក្រម ។ ចៅក្រមថ្លឹងថ្លែងពិចារណាទៅ រកឃើញទោសនាងព្រានជាអ្នកបង្កហេតុមុន ក៏ជំនុំជំរះកាត់ក្តីលក់ពិន័យនាងនោះ តាមទោសទាំងនោះទៅ ។



Some neighbors were patient, and some others reacted to her with very angry and went to sue the judge. The judge considered and found the faults of her, so he penalized what she did wrongs.



ថ្លៃងពីចៅព្រាន កាលប្រើកូនឱ្យទៅផ្ទះហើយ ក៏ស្រាតខោអាវដាក់លើមាត់ច្រាំង រួចចុះទឹក មុជស្ទូតាមខ្សែសន្ទូចបំណងដើម្បីទៅដោះត្រី ។ លុះមុជទៅក្រោម ក៏ប៉ះនឹងជង្គត់ឈើ ត្រូវចំចុងកន្ទុយភ្នែក ។



Talk about the fisherman. After, his son went home. He toke clothes off and put them on the bank of the tributary and dived along the line of fishing pole in aim to take a big fish from the hook. When he dived into the water, his head hit a stump and the edge of his eye was scratched.



ឫសឈើធ្លូតសាច់ព្រានឱ្យហូរឈាម និងឈឺផ្សា។ នាយខំស្ទាបរាវរកត្រី មិនឃើញ ឃើញតែឫសឈើជាប់ផ្លែសន្ទូច ក៏ខំងើបឡើងវិញទាំងចុកចាប់ យកដៃខ្ទប់មុខរបួសជាប់ ។ ដល់ពេលគាត់វារឡើងច្រាំងទៅយកខោអាវស្លៀក ស្រាប់តែមានខ្យល់ព្យុះកំបុតត្បូងមួយ មកកួចឆក់យកសំលៀកបំពាក់នោះបន្ថែម ឱ្យអន្តរធានទៅទៀត ។



The root of tree scratched the fisherman's flesh until bleeding. He was very hurt. When the fisherman searched for a big fish he could not found it at all. He saw only the root of tree hung on his fishing hook. He tried to get up from the water with suffering. He covered his injure with his hand. As he got up of the water, immediately the server storm swirled his clothes and destroyed it.

ចៅព្រានគ្មានអ្វីបិទបាំងកាយ ពួនត្រាំក្នុងទឹកក្បែរដើមឈូក កើតក្តីសៅហ្មងដោយឈឺងទាមផង ឈឺភ្នែកផង ។ ថែមរងរងាក្នុងទឹកយូរទ្រាំលែងបាន ចៅនោះលបរត់ឡើងគោក សម្រុកសំដៅទៅគុម្ពោតព្រៃ ធ្វើឱ្យផ្អើលដល់អស់សត្វ ។



The fisherman was in naked and soaked in water near the lotus plant. He was uncomfortable because his eye was hurt and his body was suck by leeches. He was cold and could not endure while he stayed in the water for along time. He came out of water, and ran quickly toward a bush and startled to all animals.



ព្រានសន្ទូចនៅពួនជ្រកក្នុងគុម្ពោតព្រៃ រហូតអស់សែងព្រះអាទិត្យ ទើបធ្វើដំណើរទៅផ្ទះ ។ ពេលមកដល់ផ្ទះ នាយព្រាននៅចូលពួនក្នុងបន្ទប់ទឹកឯដីទៀត មិនហ៊ានឡើងលើទេ ដ្បិតឃើញប្រពន្ធកូននៅជុំគ្នា អុចភ្លើងភ្លឺទែង ។ នាងប្រពន្ធយកសំពត់ឱ្យប្ដីស្លៀកទាំងងឿងឆ្ងល់ និងហួសចិត្ត ។ យប់នោះគ្រួសារចៅព្រាន នាំគ្នាហូបបាយទទេ បណ្ដោះអាសន្នបំពេញក្រពះ។ គេនាំគ្នាដេកហេវមួយយប់វាល់ភ្លឺ លុះព្រឹកទើបរកបានម្ហូបមកហូបសងបង្គ្រប់វិញ។



The fisherman hided his body in the bush until the Sun set. Just then he went to home. As he arrived at home he hided himself in a bathroom at the ground. He did not go up his house because his wife and son sat together and the bright of light was very bright. The wife of the fisherman took clothes and gave it to him with astonished and unreasonable. At that night day, the family of fisherman has only rice for eat no meal. They were very hungry full night. The next morning, they searched meal to satisfy their hungry.

ប្តីប្រពន្ធព្រានកំណាញ់លោភ ទទួលរងនូវក្តីវិនាស តាមរឿងដែលគេធ្វើខុសដោយសោកសៅក្តៅចិត្ត ។ ប្តីបានក្តីវិនាសខាងផ្លូវព្រៃ ដោយរកត្រីពុំបាន អស់សំពត់ស្លៀក រីសោតឯភ្នែកក៏បែកទៀត ។ ចំណែកប្រពន្ធបានក្តីវិនាសខាងផ្លូវផ្ទះ ដោយចាញ់ក្តីពួកញាតិ ត្រូវសងជំងឺចិត្តគេ ធ្វើឱ្យបង់ខាតដល់ទ្រព្យធន ។

The selfish of the fisherman family got loss according to their faults. This spouse was very sad. The husband side got loss of his fishing. He could not earn fish at all, no clothes to wear. In addition, his eye was scratched. For the wife side got loss at home because of the judge penalized her. She lost the court action of her neighbors. She must pay to the neighbors. She lost her property.

**The End**